**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ៩៩៦ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១២

# ប្រកាសរួម
# ស្តីពី
# ការផ្តល់ទឹកប្រាក់លើកទឹកចិត្តជូន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ និងអនុក្រឹត្យពាក់ព័ន្ធ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- យោងប្រកាសរួមលេខ ៩៩៥ សហវ. ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**ប្រការ ១** :

ត្រូវបានផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋបាលថ្នាក់ក្រោមជាតិ(សាលារាជធានី ខេត្ត សាលាក្រុង ស្រុក ខណ្ឌ សាលាឃុំ សង្កាត់) សម្រាប់ឧបត្ថម្ភជូនមន្ត្រីដែលបំពេញភារកិច្ចផ្ទាល់ និងមន្ត្រីផ្សេងៗទៀត លើការបម្រើសេវាសាធារណៈ ព្រមទាំងសម្រាប់ពង្រឹងយន្តការប្រមូលចំណូល។

**ប្រការ ២** :

ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តនេះ ត្រូវបានបែងចែកដាច់ដោយឡែកពីគ្នា រវាងរដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននៃការបែងចែកភារកិច្ចក្នុងការផ្តល់សេវាសាធារណៈ ដែលអនុវត្តដោយរដ្ឋបាលកណ្តាល និងការផ្តល់សេវាសាធារណៈ ដែលអនុវត្តដោយមន្ទីរជំនាញរាជធានី ខេត្ត។

**ប្រការ ៣** :

អនុញ្ញាតឱ្យរដ្ឋបាលកណ្តាលនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត កាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់ ដោយដកយកពីប្រាក់ចំណូលដែលប្រមូលបានរៀងៗខ្លួនពីការផ្តល់សេវាសាធារណៈ ដូចបានកំណត់ដោយប្រកាសរួមលេខ ៩៩៥ សហវ. ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ការកាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់នេះ ត្រូវបានចាត់ទុកថា ថវិកាជាតិបានបើកផ្តល់ជាប្រាក់បុរេប្រទានជូនរដ្ឋបាលកណ្តាលនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត សម្រាប់ការចំណាយឧបត្ថម្ភជូនមន្ត្រី និងពង្រឹងយន្តការប្រមូលចំណូល ដែលបានកំណត់នៅក្នុងប្រការ១ នៃប្រកាសរួមនេះ។ ប្រាក់រង្វាន់ដែលអនុញ្ញាតឱ្យកាត់ទុកជាមុននេះ រួមមានចំណែកប្រាក់រង្វាន់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចំណែកប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងចំណែកប្រាក់រង្វាន់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានការពាក់ព័ន្ធ។

**ប្រការ ៤** :

ការផ្តល់ប្រាក់រង្វាន់ជូនរដ្ឋបាលកណ្តាល មន្ទីរជំនាញរាជធានី ខេត្ត និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានការពាក់ព័ន្ធ ត្រូវបានកំណត់ជាសមាមាត្រភាគរយធៀបទៅនឹងប្រាក់ចំណូលប្រមូលបាន តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធភ្ជាប់ជាមួយនឹងប្រកាសរួមនេះ។

**ប្រការ ៥** :

រដ្ឋបាលកណ្តាលនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់រាជធានី ខេត្ត ត្រូវគ្រោងចំណូល និងចំណាយដែលជាកម្មវត្ថុសម្រាប់ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត នៅក្នុងគម្រោងចំណូល និងចំណាយនៃថវិកាប្រចាំឆ្នាំរបស់ខ្លួនដោយឡែកពីគ្នា។ រដ្ឋបាលកណ្តាលនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវគ្រោងឥណទានប្រាក់រង្វាន់ ដោយគិតបញ្ចូលរួមទាំងឥណទានសម្រាប់ការចំណាយលើប្រាក់រង្វាន់របស់រដ្ឋបាលកណ្តាលនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ត្រូវគ្រោងឥណទានប្រាក់រង្វាន់ ដោយគិតបញ្ចូលរួមទាំងឥណទានសម្រាប់ការចំណាយលើប្រាក់រង្វាន់របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត។

រាល់ប្រតិបត្តិការនៃចំណូល និងចំណាយទាំងនេះ ត្រូវកត់ត្រាឆ្លុះបញ្ចាំងក្នុងថវិកាជាតិ ដូចប្រតិបត្តិការនៃចំណូល និងចំណាយដទៃទៀតរបស់រដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដែរ។ ឥណទានដែលបានគ្រោងសម្រាប់ការចំណាយលើប្រាក់រង្វាន់នេះ ជាកម្មវត្ថុនៃការធ្វើអាណត្តិបើកប្រាក់ ដើម្បីទូទាត់ជាមួយចំនួនទឹកប្រាក់ដែលចាត់ទុកថាបានបុរេប្រទានពីថវិកាជាតិ(ប្រាក់ចំណូលដែលបានកាត់ទុកជាមុន)។

ការកត់ត្រាចំណូល និងចំណាយក្នុងកិច្ចប្រតិបត្តិការថវិកាជាតិ លើការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវអនុវត្តតាមនីតិវិធីទូទាត់ប្រាក់បុរេប្រទាន ដូចខាងក្រោម ៖

ក. ផ្នែកចំណូលៈត្រូវធ្វើសលាកប័ត្រចំណូលថវិកាជាតិ នូវចំនួនទឹកប្រាក់ដែលបានបុរេប្រទាន ៖

- ចំពោះរដ្ឋបាលកណ្តាលនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវរៀបចំ និងបញ្ជូនសលាកប័ត្រចំណូលថវិកាជាតិ មកនាយកដ្ឋានចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្ថានភាព ស្តីពីការអនុវត្តចំណូល និងតារាងស្តីពីការគណនាប្រាក់រង្វាន់ ព្រមទាំងរបាយការណ៍ ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក។ នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ ត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកប័ត្រ។
- ចំពោះមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់រាជធានី ខេត្តត្រូវរៀបចំ និងបញ្ជូនសលាកប័ត្រចំណូលថវិកាជាតិ មកមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ដោយភ្ជាប់មកជាមួយនូវរបាយ-ការណ៍ស្ថានភាព ស្តីពីការអនុវត្តចំណូល និងតារាង ស្តីពីការគណនាប្រាក់រង្វាន់ ព្រមទាំងរបាយ-ការណ៍ ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក។ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្តត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកប័ត្រ។

ខ. ផ្នែកចំណាយៈ ត្រូវធ្វើអាណត្តិបើកប្រាក់ ដោយចុះចំនួនទឹកប្រាក់ស្មើនឹងចំនួនទឹកប្រាក់បុរេប្រទានដែលបានចុះនៅក្នុងសលាកប័ត្រចំណូលថវិកាជាតិ។

**ប្រការ ៦** :

ក្រោយពីបានបំពេញនីតិវិធី ដែលមានចែងក្នុងប្រការ ៥ ខាងលើ ការបើកផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវអនុវត្ត ដូចខាងក្រោម ៖

ក. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

ខ. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

**ប្រការ ៧** :

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសរួមនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៨** :

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រោមឱវាទក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**អ៊ឹម ឈុនលឹម**

ចម្លងជូនៈ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- គ្រប់រដ្ឋបាលរាជធានី ខេត្ត

«ដើម្បីជូនជ្រាប»
- ដូចប្រការ ៨ «ដើម្បីអនុវត្ត»
- ឯកសារ - កាលប្បវត្តិ

## តារាងឧបសម្ព័ន្ធ
## ភ្ជាប់នឹងប្រកាសរួមលេខ ៩៩៦ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២
## ស្តីពីការផ្តល់ទ្វាន់លើកទឹកចិត្ត ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

| ល.រ | បរិយាយ | អត្រាបែងចែក | | | | | |
|---|---|---|---|---|---|---|---|
| | | ថវិកាថ្នាក់ជាតិ | ក.ជនស ឬមន្ទីរជនសស រាជធានីខេត្ត | ក.សហវ ឬមន្ទីរសហវ រាជធានីខេត្ត | រដ្ឋបាលថ្នាក់ក្រោមជាតិ | | |
| | | | | | រាជធានី ខេត្ត | ក្រុង ស្រុក ខណ្ឌ | ឃុំ សង្កាត់ |
| I - សេវាសុរិយោដី និងភូមិសាស្ត្រ | | | | | | | |
| 1 | ការចុះបញ្ជីលើកដំបូង ដែលមានលក្ខណៈជាប្រព័ន្ធ (ក្នុង 1ម$^2$) | | | | | | |
| 1.1 | ដីផលិតកម្មកសិកម្មជនបទ | 30% | 49% | 1% | 5% | 5% | 10% |
| 1.2 | ដីលំនៅដ្ឋានជនបទ | 30% | 49% | 1% | 5% | 5% | 10% |
| 1.3 | ដីលំនៅដ្ឋានទីប្រជុំជនស្រុក ឬជាយទីប្រជុំជនខេត្ត | 30% | 49% | 1% | 5% | 5% | 10% |
| 1.4 | ដីលំនៅដ្ឋានទីប្រជុំជនខេត្ត ឬជាយទីប្រជុំជនរាជធានីភ្នំពេញ | 30% | 49% | 1% | 5% | 5% | 10% |
| 1.5 | ដីលំនៅដ្ឋានទីប្រជុំជនរាជធានីភ្នំពេញ | 30% | 49% | 1% | 5% | 5% | 10% |
| 2 | ការចុះបញ្ជីដីលើកដំបូងមានលក្ខណៈដាច់ដោយដុំ និងចេញប័ណ្ណ (ក្នុង 1ក្បាលដី) | | | | | | |
| 2.1 | ដីផលិតកម្ម ឬដីភោគៈ គ្រប់ខេត្ត និងរាជធានី | 30% | 49% | 1% | 5% | 5% | 10% |

| ល.រ | បរិយាយ | អត្រាបែងចែក | | | | | |
|---|---|---|---|---|---|---|---|
| | | ថវិកាថ្នាក់ជាតិ | ក.ជនស ឬមន្ទីរជនសស រាជធានី ខេត្ត | ក.សហវ ឬមន្ទីរសហវ រាជធានី ខេត្ត | រដ្ឋបាលថ្នាក់ក្រោមជាតិ | | |
| | | | | | រាជធានី ខេត្ត | ក្រុង ស្រុក ខណ្ឌ | ឃុំ សង្កាត់ |
| 2.2 | ដីលំនៅដ្ឋាន និងដីសម្រាប់សំណង់ទូទៅ | | | | | | |
| | - ដីក្នុងរាជធានីភ្នំពេញ ឬក្នុងក្រុងខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | 30% | 49% | 1% | 5% | 5% | 10% |
| | - ដីក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | 30% | 49% | 1% | 5% | 5% | 10% |
| | - ដីជនបទ ឬក្រៅក្រុង | 30% | 49% | 1% | 5% | 5% | 10% |
| 2.3 | ការចេញប័ណ្ណទុតិយតា ឬតតិយតា | | | | | | |
| | - សម្រាប់ដីលំនៅដ្ឋាន | 30% | 49% | 1% | 5% | 5% | 10% |
| | - សម្រាប់ដីផលិតកម្ម ឬដីភោគៈ | 30% | 49% | 1% | 5% | 5% | 10% |
| 3 | ការផ្ទេរអចលនវត្ថុទាំងមូល (ក្នុង 1ប័ណ្ណ) | | | | | | |
| 3.1 | ដីផលិតកម្ម ឬដីភោគៈ គ្រប់ខេត្ត និងរាជធានី | 30% | 49% | 1% | 5% | 5% | 10% |
| 3.2 | ដីលំនៅដ្ឋាន និងដីសម្រាប់សំណង់ទូទៅ | | | | | | |
| | - ដីក្នុងរាជធានី ឬក្នុងក្រុងខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | 30% | 49% | 1% | 5% | 5% | 10% |
| | - ដីក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | 30% | 49% | 1% | 5% | 5% | 10% |
| | - ដីជនបទ ឬក្រៅក្រុង | 30% | 49% | 1% | 5% | 5% | 10% |
| 4 | ការបំបែកក្បាលដីដោយផ្ទេរ ឬដោយមិនផ្ទេរអចលនវត្ថុ (ក្នុង 1ក្បាលដីដែលបំបែក) និងការបង្រួមក្បាលដី (ក្នុង 1ក្បាលដីដើម) (តាមការស្នើសុំ) | | | | | | |
| 4.1 | ដីផលិតកម្ម ឬដីភោគៈ គ្រប់ខេត្ត និងរាជធានី | 30% | 49% | 1% | 5% | [illegible] | 10% |

| ល.រ | បរិយាយ | អត្រាបែងចែក | | | | | |
|---|---|---|---|---|---|---|---|
| | | ថវិកាថ្នាក់ជាតិ | ក.ជនស ឬមន្ទីរជនសស រាជធានី ខេត្ត | ក.សហវ ឬមន្ទីរសហវ រាជធានី ខេត្ត | រដ្ឋបាលថ្នាក់ក្រោមជាតិ | | |
| | | | | | រាជធានី ខេត្ត | ក្រុង ស្រុក ខណ្ឌ | ឃុំ សង្កាត់ |
| 4.2 | ដីលំនៅដ្ឋាន និងដីសម្រាប់សំណង់ទូទៅ | | | | | | |
| | - ដីក្នុងរាជធានី ឬក្នុងក្រុងខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | 30% | 49% | 1% | 5% | 5% | 10% |
| | - ដីក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | 30% | 49% | 1% | 5% | 5% | 10% |
| | - ដីជនបទ ឬក្រៅក្រុង | 30% | 49% | 1% | 5% | 5% | 10% |
| 5 | ការស្វែងរកចំណុចព្រំដីឡើងវិញ ( ក្នុង ១បង្គោល ) | | | | | | |
| 5.1 | ដីផលិតកម្ម ឬដីកោគៈ គ្រប់ខេត្ត និងរាជធានី | 30% | 49% | 1% | 5% | 5% | 10% |
| 5.2 | ដីលំនៅដ្ឋាន និងដីសម្រាប់សំណង់ទូទៅ | | | | | | |
| | - ដីក្នុងរាជធានី ឬក្នុងក្រុងខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | 30% | 49% | 1% | 5% | 5% | 10% |
| | - ដីក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | 30% | 49% | 1% | 5% | 5% | 10% |
| | - ដីជនបទ ឬក្រៅក្រុង | 30% | 49% | 1% | 5% | 5% | 10% |
| 6 | ការចេញលិខិតបញ្ជាក់ព័ត៌មានសុរិយោដី ក្នុង ១ក្បាលដី ( ការចេញលិខិតបញ្ជាក់ ការចេញសលាកប័ត្រព័ត៌មាន ការចេញលិខិតបញ្ជាក់សុរិយោដី ) | 10% | 89% | 1% | 0% | 0% | 0% |
| 7 | ការដាក់បន្ទុក និងការលើកលែង ៖ ឯកសិទ្ធិ ការដាក់បញ្ចាំ និងការដាក់ហ៊ីប៉ូតែក ( ក្នុង ១ក្បាលដី ឬ ១ប័ណ្ណ ) | | | | | | |
| 7.1 | ការដាក់បន្ទុក( ឯកសិទ្ធិ ការដាក់បញ្ចាំ និងការដាក់ហ៊ីប៉ូតែក ) | 30% | 49% | 1% | 5% | 5% | 10% |
| 7.2 | ការលើកលែងបន្ទុក ( ឯកសិទ្ធិ ការដាក់បញ្ចាំ និងការដាក់ហ៊ីប៉ូតែក ) | 30% | 49% | 1% | 5% | 5% | 10% |

| ល.រ | បរិយាយ | អត្រាបែងចែក | | | | | |
|---|---|---|---|---|---|---|---|
| | | ថវិកាថ្នាក់ជាតិ | ក.ដនសស ឬមន្ទីរ ដនសស រាជធានី ខេត្ត | ក.សហវ ឬមន្ទីរ សហវ រាជធានី ខេត្ត | រដ្ឋបាលថ្នាក់ក្រោមជាតិ | | |
| | | | | | រាជធានី ខេត្ត | ក្រុង ស្រុក ខណ្ឌ | ឃុំ សង្កាត់ |
| 8 | ការថតចម្លងឯកសារសុរិយោដី ( ក្នុង 1ទំព័រក្រដាស់ A4 ) | 10% | 89% | 1% | 0% | 0% | 0% |
| 9 | ការប្តូរប្រភេទដី ( ក្នុង 1ម $^2$ ) | 30% | 49% | 1% | 5% | 5% | 10% |
| 10 | ការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ ( ក្នុង 1ចំណែកឯកជន ) | | | | | | |
| | - ការចុះបញ្ជី និងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជនទូទៅ ឬវិញ្ញាបនបត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍នៃចំណែកឯកជនទូទៅ | 30% | 49% | 1% | 5% | 5% | 10% |
| | - ការចុះបញ្ជីផ្ទេរសិទ្ធិលើចំណែកឯកជនទូទៅ | 30% | 49% | 1% | 5% | 5% | 10% |
| | - ការចុះបញ្ជី និងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជន សម្រាប់អគារសហកម្មសិទ្ធដែលរដ្ឋ, សប្បុរសជន ឬអង្គការមនុស្សធម៌នានាផ្តល់ឱ្យ | 30% | 49% | 1% | 5% | 5% | 10% |
| | - ការចុះបញ្ជីផ្ទេរសិទ្ធិលើចំណែកឯកជនសម្រាប់អគារសហកម្មសិទ្ធដែលរដ្ឋ, សប្បុរសជន ឬអង្គការមនុស្សធម៌នានាផ្តល់ឱ្យ | 30% | 49% | 1% | 5% | 5% | 10% |
| 11 | ការចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ ( ក្នុង 1ប័ណ្ណ ) | | | | | | |
| | - ការចុះបញ្ជី និងចេញប័ណ្ណវិញ្ញាបនបត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍ | 30% | 49% | 1% | 5% | 5% | 10% |
| | - ចុះបញ្ជីផ្ទេរសិទ្ធិជួលអចិន្ត្រៃយ៍ | 30% | 49% | 1% | 5% | 5% | 10% |

| ល.រ | បរិយាយ | អត្រាបែងចែក | | | | | |
|---|---|---|---|---|---|---|---|
| | | ថវិកាថ្នាក់ជាតិ | ក.ដនសស ឬមន្ទីរដនសស រាជធានី ខេត្ត | ក.សហវ ឬមន្ទីរសហវ រាជធានី ខេត្ត | រដ្ឋបាលថ្នាក់ក្រោមជាតិ: រាជធានី ខេត្ត | រដ្ឋបាលថ្នាក់ក្រោមជាតិ: ក្រុង ស្រុក ខណ្ឌ | រដ្ឋបាលថ្នាក់ក្រោមជាតិ: ឃុំ សង្កាត់ |
| 12 | ការចុះបញ្ជីសិទ្ធិសម្បទានដីសេដ្ឋកិច្ច (ក្នុង 1ប័ណ្ណ) | | | | | | |
| | - ការចុះបញ្ជី និងចេញវិញ្ញាបនបត្រសម្គាល់សិទ្ធិសម្បទានដីសេដ្ឋកិច្ច | 30% | 49% | 1% | 5% | 5% | 10% |
| | - ចុះបញ្ជីផ្ទេរសិទ្ធិសម្បទានដីសេដ្ឋកិច្ច | 30% | 49% | 1% | 5% | 5% | 10% |
| 13 | ការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី (ក្នុង 1ប័ណ្ណ) | | | | | | |
| 13.1 | ការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ (ការរឹបអូសកម្មសិទ្ធិ ឬសិទ្ធិជួលអចិន្ត្រៃយ៍ ឬផលុបភោគ) | 10% | 89% | 1% | 0% | 0% | 0% |
| 13.2 | ការចុះបញ្ជីអំពីការលុបការរឹបអូសអចលនវត្ថុ (ការរឹបអូសកម្មសិទ្ធិ ឬសិទ្ធិជួលអចិន្ត្រៃយ៍ ឬផលុបភោគ) | 10% | 89% | 1% | 0% | 0% | 0% |
| 13.3 | ការចុះបញ្ជីអំពីការផ្ទេរសិទ្ធិ ការលុបការចុះបញ្ជីអំពីលទ្ធកម្មនូវសិទ្ធិ ការលុបការចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្ន ការលុបការចុះបញ្ជីអំពីការរឹបអូស ឬការរឹបអូសជាបណ្តោះអាសន្ន | | | | | | |
| 13.3.1 | ដីផលិតកម្ម ឬដីភោគៈ គ្រប់ខេត្ត និងរាជធានី | 10% | 89% | 1% | 0% | 0% | 0% |
| 13.3.2 | ដីលំនៅដ្ឋាន និងដីសម្រាប់សំណង់ទូទៅ | | | | | | |
| | - ដីក្នុងរាជធានី ឬក្នុងក្រុងខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | 10% | 89% | 1% | 0% | 0% | 0% |
| | - ដីក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | 10% | 89% | 1% | 0% | 0% | 0% |

| ល.រ | បរិយាយ | អត្រាបែងចែក | | | | | |
|---|---|---|---|---|---|---|---|
| | | ថវិកាថ្នាក់ជាតិ | ក.ជនស ឬមន្ទីរជនសស រាជធានី ខេត្ត | ក.សហវ ឬមន្ទីរសហវ រាជធានី ខេត្ត | រដ្ឋបាលថ្នាក់ក្រោមជាតិ | | |
| | | | | | រាជធានី ខេត្ត | ក្រុង ស្រុក ខណ្ឌ | ឃុំ សង្កាត់ |
| | - ដីជនបទ ឬក្រៅក្រុង | 10% | 89% | 1% | 0% | 0% | 0% |
| 13.4 | ការចុះបញ្ជីអតិ:<br>1.ការរើបអូសចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀត<br>2.ការរើបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ (កម្មសិទ្ធិ ឬសិទ្ធិជួលអចិន្ត្រៃយ៍ ឬផលុបភោគ)<br>3.ការរើបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិ លើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀត<br>4.ការចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ (កម្មសិទ្ធិ ឬសិទ្ធិជួលអចិន្ត្រៃយ៍ ឬផលុបភោគ) | 10% | 89% | 1% | 0% | 0% | 0% |

| ល.រ | បរិយាយ | អត្រាបែងចែក | | | | | |
|---|---|---|---|---|---|---|---|
| | | ថវិកាថ្នាក់ជាតិ | ក.ជនសស ឬមន្ទីរជនសស រាជធានី ខេត្ត | ក.សហវ ឬមន្ទីរសហវ រាជធានី ខេត្ត | រដ្ឋបាលថ្នាក់ក្រោមជាតិ | | |
| | | | | | រាជធានី ខេត្ត | ក្រុង ស្រុក ខណ្ឌ | ឃុំ សង្កាត់ |
| 13.5 | ការលុបការចុះបញ្ជីអពិៈ<br>1.ការរឹបអូសចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀត<br>2.ការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ( កម្មសិទ្ធិ ឬសិទ្ធិជួលអចិន្ត្រៃយ៍ ឬផលុបភោគ )<br>3.ការរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិ លើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀត<br>4.ការចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ ( កម្មសិទ្ធិ ឬសិទ្ធិជួលអចិន្ត្រៃយ៍ ឬផលុបភោគ ) | 10% | 89% | 1% | 0% | 0% | 0% |
| 13.6 | -ការចុះបញ្ជីអំពីការបង្កើត ឬការកែប្រែ ឬការលុបនូវសិទ្ធិ តាមសាលក្រម ឬសាលដីកា ឬដីកាសម្រេច ឬលិខិតអនុវត្តដោយផ្អែកលើការផ្សះផ្សា ឬការទទួលស្គាល់នូវការទាមទារ | 10% | 89% | 1% | 0% | 0% | 0% |
| 14 | ផែនទីជាក្រដាស ( ក្នុង 1សន្លឹក ) | | | | | | |
| 14.1 | ផែនទីហានលេខាមាត្រដ្ឋាន 1/100,000 ដែលមានស្រាប់ | 10% | 89% | 1% | 0% | 0% | 0% |
| 14.2 | សេវាបោះពុម្ពផែនទីរដ្ឋបាលនៃព្រះរាជាណាចក្រកម្ពុជា មាត្រដ្ឋាន 1/650,001 | 10% | 89% | 1% | 0% | 0% | 0% |

| ល.រ | បរិយាយ | អត្រាបែងចែក | | | | | |
|---|---|---|---|---|---|---|---|
| | | ថវិកាថ្នាក់ជាតិ | ក.ជនសស ឬមន្ទីរជនសស រាជធានី ខេត្ត | ក.សហវ ឬមន្ទីរសហវ រាជធានី ខេត្ត | រដ្ឋបាលថ្នាក់ក្រោមជាតិ | | |
| | | | | | រាជធានី ខេត្ត | ក្រុង ស្រុក ខណ្ឌ | ឃុំ សង្កាត់ |
| 15 | រូបថតអ័រតូហ្វូតូ ទំរង់ជាឌីជីថល (ក្នុង 1គ.ម$^2$) | | | | | | |
| 15.1 | អង្គភាពរដ្ឋដែលស្នើទិញ សម្រាប់តំបន់ជនបទ និងព្រៃ | 10% | 89% | 1% | 0% | 0% | 0% |
| 15.2 | អង្គភាពរដ្ឋដែលស្នើទិញ សម្រាប់តំបន់ទីប្រជុំជន និងទីក្រុង | 10% | 89% | 1% | 0% | 0% | 0% |
| 15.3 | ឯកជនដែលស្នើទិញ សម្រាប់តំបន់ជនបទ និងព្រៃ | 10% | 89% | 1% | 0% | 0% | 0% |
| 15.4 | ឯកជនដែលស្នើទិញ សម្រាប់តំបន់ទីប្រជុំជន និងទីក្រុង | 10% | 89% | 1% | 0% | 0% | 0% |
| 16 | រូបថតអ័រតូហ្វូតូទំរង់ជាក្រដាស(បោះពុម្ពជាក្រដាសខ្នាតA0) ក្នុង01សន្លឹក | 10% | 89% | 1% | 0% | 0% | 0% |
| 17 | ទិន្នន័យបង្គោលប្រថពីវិភាគ(ប្លង់ទីតាំង និងនិយាមកា) គិតក្នុង 01បង្គោល(តាមការស្នើសុំ) | | | | | | |
| 17.1 | ទិន្នន័យបង្គោលប្រថពីវិភាគថ្នាក់ជាតិលំដាប់សូន្យ | 10% | 89% | 1% | 0% | 0% | 0% |
| 17.2 | ទិន្នន័យបង្គោលប្រថពីវិភាគថ្នាក់ជាតិលំដាប់ទី1 | 10% | 89% | 1% | 0% | 0% | 0% |
| 17.3 | ទិន្នន័យបង្គោលប្រថពីវិភាគថ្នាក់ជាតិលំដាប់ទី2 | 10% | 89% | 1% | 0% | 0% | 0% |
| 17.4 | ទិន្នន័យបង្គោលប្រថពីវិភាគថ្នាក់ជាតិលំដាប់ទី3 | 10% | 89% | 1% | 0% | 0% | 0% |
| 17.5 | ទិន្នន័យបង្គោលពហុកោណគោល | 10% | 89% | 1% | 0% | 0% | 0% |

| ល.រ | បរិយាយ | អត្រាបែងចែក | | | | | |
|---|---|---|---|---|---|---|---|
| | | ថវិកាថ្នាក់ជាតិ | ក.ជនស ឬមន្ទីរជនសស រាជធានីខេត្ត | ក.សហវ ឬមន្ទីរសហវ រាជធានីខេត្ត | រដ្ឋបាលថ្នាក់ក្រោមជាតិ | | |
| | | | | | រាជធានីខេត្ត | ក្រុងស្រុក.ខណ្ឌ | ឃុំសង្កាត់ |
| I - **សេវាសំណង់** | | | | | | | |
| II-1- **លិខិតអនុញ្ញាតដែលជាសមត្ថកិច្ចរបស់សាលារាជធានី - ខេត្ត** | | | | | | | |
| 1 | សំណង់លំនៅដ្ឋាន | | | | | | |
| 1.1 | លិខិតអនុញ្ញាតសាងសង់ | | | | | | |
| 1.1.1 | ភូមិគ្រឹះ (ម$^2$) | | | | | | |
| | ≤100 | 30% | 49% | 1% | 5% | 5% | 10% |
| | ≤200 | 30% | 49% | 1% | 5% | 5% | 10% |
| | ≤300 | 30% | 49% | 1% | 5% | 5% | 10% |
| | ≤400 | 30% | 49% | 1% | 5% | 5% | 10% |
| | ≤500 | 30% | 49% | 1% | 5% | 5% | 10% |
| | ≤1000 | 30% | 49% | 1% | 5% | 5% | 10% |
| | ≤2000 | 30% | 49% | 1% | 5% | 5% | 10% |
| | ≤3000 | 30% | 49% | 1% | 5% | 5% | 10% |
| 1.1.2 | ផ្ទះល្វែង (ម$^2$) | | | | | | |
| | ≤100 | 30% | 49% | 1% | 5% | 5% | 10% |
| | ≤200 | 30% | 49% | 1% | 5% | 5% | 10% |

| ល.រ | បរិយាយ | អត្រាបែងចែក | | | | | |
|---|---|---|---|---|---|---|---|
| | | ថវិកាថ្នាក់ជាតិ | ក.ជនសស ឬមន្ទីរ ជនសស រាជធានី ខេត្ត | ក.សហវ ឬមន្ទីរ សហវ រាជធានី ខេត្ត | រដ្ឋបាលថ្នាក់ក្រោមជាតិ | | |
| | | | | | រាជធានី ខេត្ត | ក្រុង ស្រុក ខណ្ឌ | ឃុំ សង្កាត់ |
| | ≤300 | 30% | 49% | 1% | 5% | 5% | 10% |
| | ≤400 | 30% | 49% | 1% | 5% | 5% | 10% |
| | ≤500 | 30% | 49% | 1% | 5% | 5% | 10% |
| | ≤1000 | 30% | 49% | 1% | 5% | 5% | 10% |
| | ≤2000 | 30% | 49% | 1% | 5% | 5% | 10% |
| | ≤3000 | 30% | 49% | 1% | 5% | 5% | 10% |
| 1.1.3 | ផ្ទះថ្មក្រោមឈើលើ ($ម^2$) | | | | | | |
| | ≤100 | 30% | 49% | 1% | 5% | 5% | 10% |
| | ≤200 | 30% | 49% | 1% | 5% | 5% | 10% |
| | ≤300 | 30% | 49% | 1% | 5% | 5% | 10% |
| | ≤400 | 30% | 49% | 1% | 5% | 5% | 10% |
| | ≤500 | 30% | 49% | 1% | 5% | 5% | 10% |
| | ≤1000 | 30% | 49% | 1% | 5% | 5% | 10% |
| | ≤2000 | 30% | 49% | 1% | 5% | 5% | 10% |
| | ≤3000 | 30% | 49% | 1% | 5% | 5% | 10% |
| 1.2 | លិខិតអនុញ្ញាតសាងសង់ពង្រីកបន្ថែមរុះរើជួសជុល | 10% | 89% | 1% | 0% | 0% | 0% |

| ល.រ | បរិយាយ | អត្រាបែងចែក | | | | | |
|---|---|---|---|---|---|---|---|
| | | ថវិកាថ្នាក់ជាតិ | ក.ដនស ឬមន្ទីរដនសស រាជធានី ខេត្ត | ក.សហវ ឬមន្ទីរសហវ រាជធានី ខេត្ត | រដ្ឋបាលថ្នាក់ក្រោមជាតិ | | |
| | | | | | រាជធានី ខេត្ត | ក្រុង ស្រុក ខណ្ឌ | ឃុំ សង្កាត់ |
| 1.3 | លិខិតអនុញ្ញាតបើកការដ្ឋាន | 10% | 89% | 1% | 0% | 0% | 0% |
| 1.4 | លិខិតបិទការដ្ឋាន ឬវិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវ | 10% | 89% | 1% | 0% | 0% | 0% |
| 2 | សំណង់អគារផ្សេងៗក្រៅពីលំនៅឋាន | | | | | | |
| 2.1 | លិខិតអនុញ្ញាតសាងសង់ (ម$^2$) | | | | | | |
| | ≤100 | 30% | 49% | 1% | 5% | 5% | 10% |
| | ≤200 | 30% | 49% | 1% | 5% | 5% | 10% |
| | ≤300 | 30% | 49% | 1% | 5% | 5% | 10% |
| | ≤400 | 30% | 49% | 1% | 5% | 5% | 10% |
| | ≤500 | 30% | 49% | 1% | 5% | 5% | 10% |
| | ≤1000 | 30% | 49% | 1% | 5% | 5% | 10% |
| | ≤2000 | 30% | 49% | 1% | 5% | 5% | 10% |
| | ≤3000 | 30% | 49% | 1% | 5% | 5% | 10% |
| 2.2 | លិខិតអនុញ្ញាតសាងសង់ពង្រីកបន្ថែមរុះរើជួសជុល | 10% | 89% | 1% | 0% | 0% | 0% |
| 2.3 | លិខិតអនុញ្ញាតបើកការដ្ឋាន | 10% | 89% | 1% | 0% | 0% | 0% |
| 2.4 | លិខិតបិទការដ្ឋាន ឬវិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវ | 10% | 89% | 1% | 0% | 0% | 0% |

| ល.រ | បរិយាយ | អត្រាបែងចែក | | | | | |
|---|---|---|---|---|---|---|---|
| | | ថវិកាថ្នាក់ជាតិ | ក.ជនស ឬមន្ទីរជនសស រាជធានីខេត្ត | ក.សហវ ឬមន្ទីរសហវ រាជធានីខេត្ត | រដ្ឋបាលថ្នាក់ក្រោមជាតិ: រាជធានី ខេត្ត | ក្រុង ស្រុក ខណ្ឌ | ឃុំ សង្កាត់ |
| 3 | សំណង់រដ្ឋ សំណង់សប្បុរសជន ឬអង្គការមនុស្សធម៌ អំណោយជូនសហគមន៍ ឬជនក្រីក្រ ( ទំហំ ≤3.000ម$^2$) | | | | | | |
| 3.1 | លិខិតអនុញ្ញាតសាងសង់ | 0% | 0% | 0% | 0% | 0% | 0% |
| 3.2 | លិខិតអនុញ្ញាតសាងសង់ពង្រីកបន្ថែមរុះរើជួសជុល | 0% | 0% | 0% | 0% | 0% | 0% |
| 3.3 | លិខិតអនុញ្ញាតបើកការដ្ឋាន | 0% | 0% | 0% | 0% | 0% | 0% |
| 3.4 | លិខិតបិទការដ្ឋាន ឬវិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវ | 0% | 0% | 0% | 0% | 0% | 0% |
| **II-2-លិខិតអនុញ្ញាតដែលជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** | | | | | | | |
| 4 | សំណង់ឯកជន | | | | | | |
| 4.1 | លិខិតអនុញ្ញាតសាងសង់ | | | | | | |
| 4.1.1 | សំណង់លំនៅឋាន (ម$^2$) | | | | | | |
| | ≤4000 | 30% | 49% | 1% | 5% | 5% | 10% |
| | ≤6000 | 30% | 49% | 1% | 5% | 5% | 10% |
| | ≤10000 | 30% | 49% | 1% | 5% | 5% | 10% |
| | ≤20000 | 30% | 49% | 1% | 5% | 5% | 10% |
| | ≤40000 | 30% | 49% | 1% | 5% | 5% | 10% |

| ល.រ | បរិយាយ | អត្រាបែងចែក | | | | | |
|---|---|---|---|---|---|---|---|
| | | ថវិកាថ្នាក់ជាតិ | ក.ជនស ឬមន្ទីរ ជនសស រាជធានី ខេត្ត | ក.សហវ ឬមន្ទីរ សហវ រាជធានី ខេត្ត | រដ្ឋបាលថ្នាក់ក្រោមជាតិ: រាជធានី ខេត្ត | រដ្ឋបាលថ្នាក់ក្រោមជាតិ: ក្រុង ស្រុក ខណ្ឌ | រដ្ឋបាលថ្នាក់ក្រោមជាតិ: ឃុំ សង្កាត់ |
| | ≤60000 | 30% | 49% | 1% | 5% | 5% | 10% |
| | ≤100000 | 30% | 49% | 1% | 5% | 5% | 10% |
| | >100000 | 30% | 49% | 1% | 5% | 5% | 10% |
| 4.1.2 | សំណង់អគារផ្សេងៗក្រៅពីលំនៅឋាន (ម$^2$) | | | | | | |
| | ≤4000 | 30% | 49% | 1% | 5% | 5% | 10% |
| | ≤6000 | 30% | 49% | 1% | 5% | 5% | 10% |
| | ≤10000 | 30% | 49% | 1% | 5% | 5% | 10% |
| | ≤20000 | 30% | 49% | 1% | 5% | 5% | 10% |
| | ≤40000 | 30% | 49% | 1% | 5% | 5% | 10% |
| | ≤60000 | 30% | 49% | 1% | 5% | 5% | 10% |
| | ≤100000 | 30% | 49% | 1% | 5% | 5% | 10% |
| | >100000 | 30% | 49% | 1% | 5% | 5% | 10% |
| 4.2 | លិខិតអនុញ្ញាតសាងសង់ពង្រីកបន្ថែមរុះរើជួសជុល | 10% | 89% | 1% | 0% | 0% | 0% |
| 4.3 | លិខិតអនុញ្ញាតបើកការដ្ឋាន | 10% | 89% | 1% | 0% | 0% | 0% |
| 4.4 | លិខិតបិទការដ្ឋាន ឬវិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវ | 10% | 89% | 1% | 0% | 0% | 0% |

| ល.រ | បរិយាយ | អត្រាបែងចែក | | | | | |
|---|---|---|---|---|---|---|---|
| | | ថវិកាថ្នាក់ជាតិ | ក.ដនសស ឬមន្ទីរដនសស រាជធានី ខេត្ត | ក.សហវ ឬមន្ទីរសហវ រាជធានី ខេត្ត | រដ្ឋបាលថ្នាក់ក្រោមជាតិ | | |
| | | | | | រាជធានី ខេត្ត | ក្រុង ស្រុក ខណ្ឌ | ឃុំ សង្កាត់ |
| 5 | សំណង់រដ្ឋ សំណង់សប្បុរសជន ឬអង្គការមនុស្សធម៌ អំណោយជូនសហគម ឬជនក្រីក្រ ( ទំហំ > 3.000ម$^2$ ) | | | | | | |
| 5.1 | លិខិតអនុញ្ញាតសាងសង់ | 0% | 0% | 0% | 0% | 0% | 0% |
| 5.2 | លិខិតអនុញ្ញាតសាងសង់ពង្រីកបន្ថែមរុះរើជួសជុល | 0% | 0% | 0% | 0% | 0% | 0% |
| 5.3 | លិខិតអនុញ្ញាតបើកការដ្ឋាន | 0% | 0% | 0% | 0% | 0% | 0% |
| 5.4 | លិខិតបិទការដ្ឋាន ឬវិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវ | 0% | 0% | 0% | 0% | 0% | 0% |
| II-3 **ការផ្តល់គោលការណ៍សាងសង់ និងអភិវឌ្ឍន៍ដី** | | | | | | | |
| 6 | សមត្ថកិច្ចរបស់សាលារាជធានី ខេត្ត | | | | | | |
| 6.1 | ប្តូរឈ្មោះក្នុងលិខិតអនុញ្ញាតសាងសង់ និងក្នុងប្លង់ស្ថាបត្យកម្ម | 10% | 89% | 1% | 0% | 0% | 0% |
| 6.2 | បន្តសុពលភាពលិខិតអនុញ្ញាតសាងសង់ ( ក្នុងករណីមិនចាប់ផ្តើមសាងសង់ បន្ទាប់ពីបានការអនុញ្ញាតបាន 1 ឆ្នាំ និងក្នុងករណីមិនមានលិខិតអនុញ្ញាតបើកការដ្ឋានសាងសង់ ) | 10% | 89% | 1% | 0% | 0% | 0% |
| 6.3 | បន្តសុពលភាពលិខិតអនុញ្ញាតសាងសង់ពង្រីកបន្ថែមរុះរើជួសជុល ( ក្នុងករណីមិនចាប់ផ្តើមជួសជុល បន្ទាប់ពីបានការអនុញ្ញាតបាន 1 ឆ្នាំ ) | 10% | 89% | 1% | 0% | 0% | 0% |
| 7 | សមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | | | | | | |
| 7.1 | ប្តូរឈ្មោះក្នុងលិខិតអនុញ្ញាតសាងសង់ និងក្នុងប្លង់ស្ថាបត្យកម្ម | 10% | 89% | 1% | 0% | 0% | 0% |

| ល.រ | បរិយាយ | អត្រាបែងចែក | | | | | |
|---|---|---|---|---|---|---|---|
| | | ថវិកាថ្នាក់ជាតិ | ក.ដនសស | ក.សហវ | រដ្ឋបាលថ្នាក់ក្រោមជាតិ | | |
| | | | មន្ទីរ ដនសស រាជធានី ខេត្ត | មន្ទីរ សហវ រាជធានី ខេត្ត | រាជធានី ខេត្ត | ក្រុង ស្រុក ខណ្ឌ | ឃុំ សង្កាត់ |
| 7.2 | បន្តសុពលភាពលិខិតអនុញ្ញាតសាងសង់ (ក្នុងករណីមិនបានចាប់ផ្តើមសាងសង់ បន្ទាប់ពី ការអនុញ្ញាតបាន 1 ឆ្នាំ និងក្នុងករណីមិនបានស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋាន) | 10% | 89% | 1% | 0% | 0% | 0% |
| 7.3 | បន្តសុពលភាពលិខិតអនុញ្ញាតសាងសង់កែប្រែរចនាសម្ព័ន្ធ ឬជួសជុល ធ្វើជួសជុល បន្ទាប់ពីបានការអនុញ្ញាតបាន 1 ឆ្នាំ) | 10% | 89% | 1% | 0% | 0% | 0% |
| 7.4 | គោលការណ៍សាងសង់អគារតែមួយកន្លែង | 10% | 89% | 1% | 0% | 0% | 0% |
| 7.5 | គោលការណ៍សាងសង់អគារក្នុងបុរី (ផ្តល់ឲ្យតែតាមការស្នើសុំ) | 10% | 89% | 1% | 0% | 0% | 0% |
| 7.6 | លិខិតអនុញ្ញាតជាគោលការណ៍ ឬលិខិតអនុញ្ញាតអភិវឌ្ឍន៍ដីកសិកម្ម ទៅជាដីសាងសង់ (សម្រាប់បំលែងទៅជាគោលបំណងពាណិជ្ជកម្ម, ឧស្សាហកម្ម និងលំនៅឋាន) | | | | | | |
| | - ទំហំក្រោម 10 ហិកតា (ក្នុងមួយ 1ម²) | 10% | 89% | 1% | 0% | 0% | 0% |
| | - ទំហំចាប់ពី 10 ហិកតាឡើង (គិតសរុប) | 10% | 89% | 1% | 0% | 0% | 0% |
| **III- ការចុះបញ្ជីសមាសភាព-ក្រុមប្រឹក្សាសហគមន៍ជនជាតិដើមភាគតិច ក្រុមប្រឹក្សាភិបាល និងក្រុមប្រឹក្សាសហគមន៍** | | | | | | | |
| **III-1- ចុះបញ្ជីកម្មសិទ្ធិសមូហភាព សហគមន៍ និងសហគមន៍ជនជាតិដើមភាគតិច - ខេត្ត** | | | | | | | |
| 1 | ចុះបញ្ជីលើកដំបូងសម្រាប់ក្រុមជាងសំណង់ | 50% | 49% | 1% | 0% | 0% | 0% |
| 2 | បន្តសុពលភាពសម្រាប់ក្រុមជាងសំណង់ | 50% | 49% | 1% | 0% | 0% | 0% |

| ល.រ | បរិយាយ | អត្រាបែងចែក | | | | | |
|---|---|---|---|---|---|---|---|
| | | ថវិកាថ្នាក់ជាតិ | ក.ដនសស ឬមន្ទីរដនសស រាជធានី ខេត្ត | ក.សហវ ឬមន្ទីរសហវ រាជធានី ខេត្ត | រដ្ឋបាលថ្នាក់ក្រោមជាតិ | | |
| | | | | | រាជធានី ខេត្ត | ក្រុង ស្រុក ខណ្ឌ | ឃុំ សង្កាត់ |
| III-2- | **ក្នុងសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** | | | | | | |
| 1 | ចុះបញ្ជីលើកដំបូង និងបន្តសុពលភាពសម្រាប់សហគ្រាស-ក្រុមហ៊ុន ប្រកបអាជីវកម្មសំណង់ | | | | | | |
| | - ប្រភេទ 3 ( តូច ) | 50% | 49% | 1% | 0% | 0% | 0% |
| | · ប្រភេទ 2 ( មធ្យម ) | 50% | 49% | 1% | 0% | 0% | 0% |
| | - ប្រភេទ 1 ( ធំ ) | 50% | 49% | 1% | 0% | 0% | 0% |
| 2 | ដំឡើងឋានៈប្រភេទសម្រាប់សហគ្រាស-ក្រុមហ៊ុន ប្រកបអាជីវកម្មសំណង់ | | | | | | |
| | - ប្រភេទ 3 ( តូច ) ទៅប្រភេទ 2 ( មធ្យម ) | 50% | 49% | 1% | 0% | 0% | 0% |
| | - ប្រភេទ 2 ( មធ្យម ) ទៅប្រភេទ 1 ( ធំ ) | 50% | 49% | 1% | 0% | 0% | 0% |
| 3 | ចុះបញ្ជីលើកដំបូង និងបន្តសុពលភាពសម្រាប់រូបវន្តបុគ្គលសិក្សាគម្រោងប្លង់ | | | | | | |
| | - ប្រភេទ 3 ( តូច ) | 50% | 49% | 1% | 0% | 0% | 0% |
| | - ប្រភេទ 2 ( មធ្យម ) | 50% | 49% | 1% | 0% | 0% | 0% |
| | - ប្រភេទ 1 ( ធំ ) | 50% | 49% | 1% | 0% | 0% | 0% |
| 4 | ដំឡើងឋានៈកំរិតសម្រាប់រូបវន្តបុគ្គលសិក្សាគម្រោងប្លង់ | | | | | | |
| | - កំរិតទី 3(តូច) - ទៅកំរិតទី 2(មធ្យម) | 50% | 49% | 1% | 0% | 0% | 0% |
| | - កំរិតទី 2(មធ្យម) - ទៅកំរិតទី 1(ធំ) | 50% | 49% | 1% | 0% | 0% | 0% |

| ល.រ | បរិយាយ | អត្រាបែងចែក | | | | | |
|---|---|---|---|---|---|---|---|
| | | ថវិកាថ្នាក់ជាតិ | ក.ដនសស ឬមន្ទីរដនសស រាជធានី ខេត្ត | ក.សហវ ឬមន្ទីរ សហវ រាជធានី ខេត្ត | រដ្ឋបាលថ្នាក់ក្រោមជាតិ | | |
| | | | | | រាជធានី ខេត្ត | ក្រុង ស្រុក ខណ្ឌ | ឃុំ សង្កាត់ |
| **IV-ការថតចម្លងឯកសារប្លង់ និងផែនទី (តាមការស្នើសុំ)** | | | | | | | |
| 1 | ឯកសារស្នើសុំសាងសង់ (ក្នុង 1ច្បាប់) | 10% | 89% | 1% | 0% | 0% | 0% |
| 2 | ប្លង់ស្ថាបត្យកម្ម ឬប្លង់គ្រឿងផ្គុំសំណង់ (ក្នុង 1ច្បាប់) | 10% | 89% | 1% | 0% | 0% | 0% |
| 3 | ផែនទី ទំហំ A-4 (ក្នុង 1សន្លឹក) | 10% | 89% | 1% | 0% | 0% | 0% |
| 4 | ផែនទី ទំហំ A-3 (ក្នុង 1សន្លឹក) | 10% | 89% | 1% | 0% | 0% | 0% |
| 5 | ផែនទី ទំហំ A-2 (ក្នុង 1សន្លឹក) | 10% | 89% | 1% | 0% | 0% | 0% |
| 6 | ផែនទី ទំហំ A-1 (ក្នុង 1សន្លឹក) | 10% | 89% | 1% | 0% | 0% | 0% |
| 7 | ផែនទី ទំហំ A-0 (ក្នុង 1សន្លឹក) | 10% | 89% | 1% | 0% | 0% | 0% |
| **V-សេវាពិគ្រោះយោបល់លើផ្នែកច្បាប់ និងបច្ចេកទេស (តាមការស្នើសុំ)** | | | | | | | |
| 1 | នៅថ្នាក់ជាតិ (ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ -ការិយាល័យនៃលេខាធិការដ្ឋានច្រកចេញ-ចូល តែមួយ) | | | | | | |
| | - លើការងារទាក់ទងទៅនឹងដីធ្លី និងសំណង់ទូទៅ (សម្រាប់មួយករណី) | 10% | 89% | 1% | 0% | 0% | 0% |
| | - លើការងារទាក់ទងទៅនឹងតំបន់សេដ្ឋកិច្ចពិសេស ការអភិវឌ្ឍន៍កោះ ឆ្នេរ បុរី ដីសម្បទានសេដ្ឋកិច្ច និងអគារខ្ពស់ៗ (សម្រាប់មួយករណី) | 10% | 89% | 1% | 0% | 0% | 0% |

| ល.រ | បរិយាយ | អត្រាបែងចែក | | | | | |
|---|---|---|---|---|---|---|---|
| | | ថវិកាថ្នាក់ជាតិ | ក.ដនស ឬមន្ទីរដនសស រាជធានី ខេត្ត | ក.សហវ ឬមន្ទីរសហវ រាជធានី ខេត្ត | រដ្ឋបាលថ្នាក់ក្រោមជាតិ | | |
| | | | | | រាជធានី ខេត្ត | ក្រុង ស្រុក ខណ្ឌ | ឃុំ សង្កាត់ |
| 2 | នៅថ្នាក់ក្រោមជាតិ ( មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី-ខេត្ត ) | | | | | | |
| | - លើការងារទាក់ទងទៅនឹងដីធ្លី និងសំណង់ទូទៅ ( សម្រាប់មួយករណី ) | 10% | 89% | 1% | 0% | 0% | 0% |